COUNTY OF LOS ANGELES
Public Health

# ពិធីការរសម្រាប់ក្រុមកីឡាយុវជនដែលមានការរៀបចំត្រឹមត្រូវ៖ ឧបសម្ព័ន្ធ S

**បច្ចុប្បន្នភាពថ្មីៗ៖** ការផ្លាស់ប្តូរទាំងឡាយត្រូវបានរំលេចដោយពណ៌លឿង
**1/3/22:**

- បានធ្វើបច្ចុប្បន្នកម្មដើម្បីឆ្លុះបញ្ចាំងអំពីការផ្អាកនៃសកម្មភាពក្រុមទាំងអស់ចំនួនយ៉ាងហោចណាស់ 7 ថ្ងៃ សម្រាប់ក្រុមកីឡាយុវ ជនណាដែលក្នុងនោះមានការផ្ទុះឡើងនូវករណីដែលទាក់ទងនឹងការរីករាយដាលនៃជំងឺចំនួន 4 ករណីឡើងទៅក្នុងអំឡុងពេល 14 ថ្ងៃ។
- ការរឹតបន្តឹងចំពោះការពាក់ម៉ាស់ត្រូវបានពង្រីកបន្ត។ បន្ថែមពីលើការពាក់ម៉ាស់ដែលតម្រូវចាំបាច់សម្រាប់ប្រភេទកីឡានៅខាងក្នុងអគារទាំងអស់តាមដែលអាចអនុវត្តទៅបាននោះ ឥឡូវនេះការពាក់ម៉ាស់ក៏ត្រូវបានតម្រូវចាំបាច់ផងដែរសម្រាប់កីឡានៅខាងក្រៅអគារទាំងឡាយដែលមានកម្រិតហានិភ័យមធ្យមនិងខ្ពស់ ដែលការរក្សាគម្លាតមិនអាចអនុវត្តតាមការជាក់ស្តែង នៅពេលដែលអាចធ្វើទៅបាន។
- បានបន្ថែមការណែនាំ និងតំណភ្ជាប់ទំព័រទាក់ទងនឹងសេចក្តីណែនាំថ្មីៗរបស់ DPH ដើម្បីធ្វើឱ្យខ្យល់បក់ចេញចូលប្រសើរឡើងនៅក្នុងសាលហាត់កីឡា។
- បានធ្វើបច្ចុប្បន្នកម្មដើម្បីឆ្លុះបញ្ចាំងថាការកម្រិតសម្រាប់ព្រឹត្តិការណ៍ធំៗបំផុត (Mega Events) ត្រូវបានបន្ថយចំនួនអ្នកចូលរួមចុះពី 10,000 នាក់មក 5,000 នាក់ សម្រាប់ព្រឹត្តិការណ៍ធំៗបំផុតនៅខាងក្រៅអគារ និងបន្ថយចំនួនអ្នកចូលរួមចុះពី 1,000 នាក់មក 500 នាក់សម្រាប់ព្រឹត្តិការណ៍ធំៗបំផុតនៅខាងក្នុងអគារ។

**12/8/21:**
ធ្វើការផ្លាស់ប្តូរ ជាការឆ្លើយតបទៅនឹងបច្ចុប្បន្នភាពថ្មីៗទៅលើ សេចក្តីណែនាំរបស់រដ្ឋសម្រាប់សាលារៀនកម្រិត K-12 ដែលទាក់ទងនឹងសកម្មភាពក្រៅកម្មវិធីសិក្សា។ ការផ្លាស់ប្តូរជាក់លាក់នោះគឺ៖

- តម្រូវឱ្យពាក់ម៉ាស់ជានិច្ចពេលក្នុងខាងក្នុងអគារ នៅពេលដែលអ្នកចូលរួមមិនកំពុងអនុវត្តការហាត់សម ពង្រឹងសមត្ថភាព ប្រកួតប្រជែង ឬសម្តែងយ៉ាងសកម្មនោះទេ។
- អ្នកចូលរួមក្នុងកីឡាយុវជនតម្រូវឱ្យពាក់ម៉ាស់ ខណៈពេលដែលកំពុងអនុវត្តការហាត់សម ពង្រឹងសមត្ថភាព ឬប្រកួតប្រជែង យ៉ាងសកម្មនៅក្នុងកីឡាដែលរៀបចំឡើងនៅខាងក្នុងអគារ សូម្បីតែក្នុងអំឡុងពេលមានការប្រឹងប្រែងប្រើកម្លាំងយ៉ាងខ្លាំងក៏ដោយ តាមដែលអាចអនុវត្តទៅបាន។
- ប្រសិនបើក្រុមកីឡាយុវជនកំណត់ថាការតម្រូវចាំបាច់ឱ្យកីឡាករទាំងអស់ត្រូវតែពាក់ម៉ាស់ក្នុងអំឡុងពេលមានការប្រឹងប្រែងប្រើកម្លាំងយ៉ាងខ្លាំងនោះគឺមិនអាចអនុវត្តបានទេ ហើយជាលទ្ធផលសមាជិកទាំងអស់នៃក្រុមកីឡាករជ្រើសរើសចូលរួមប្រកួតដោយមិនពាក់ម៉ាស់ នោះសមាជិកទាំងអស់គឺតម្រូវចាំបាច់ឱ្យអនុវត្តការធ្វើតេស្តត្រួតពិនិត្យរកមេរោគ COVID-19 ឱ្យបានយ៉ាងហោចណាស់ម្តងក្នុងមួយសប្តាហ៍ ដោយមិនគិតពីស្ថានភាពចាក់ថ្នាំបង្ការឡើយ។
- ខណៈពេលដែលការចម្លងក្នុងសហគមន៍នៃខោនធី Los Angeles នៅតែមានកម្រិតគួរឱ្យកត់សម្គាល់ ឬកម្រិតខ្ពស់នោះ សុខភាពសាធារណៈផ្តល់ការណែនាំយ៉ាងម៉ឺងម៉ាត់ថា អ្នកចូលរួមដែលមិនបានទទួលចាក់ថ្នាំបង្ការទាំងឡាយ និងអ្នកដែលមិនតែងតែពាក់ម៉ាស់ក្នុងអំឡុងពេលកំពុងអនុវត្តការហាត់សម ពង្រឹងសមត្ថភាព ប្រកួតប្រជែង ឬសម្តែង ត្រូវមានការធ្វើតេស្តរកមេរោគ COVID-19 ឱ្យបានពីរដងក្នុងមួយសប្តាហ៍។

នៅថ្ងៃទី 17 និង 22 ខែកក្កដា មន្ត្រីសុខាភិបាលនៃខោនធី Los Angeles បានចេញការកែសម្រួលនៃ សេចក្តីបង្គាប់របស់មន្ត្រីសុខាភិបាល ដែលតម្រូវឱ្យមានការប្រើប្រាស់ម៉ាស់ នៅគ្រប់ទីតាំងសាធារណៈដែលនៅខាងក្នុងអគារទាំងអស់។ ដោយសារមានការកើនឡើងនៃការចម្លងជំងឺ COVID-19 ក្នុងសហគមន៍ និងស្ថានភាពមានចំនួនកើនឡើងច្រើននៃមេរោគ COVID-19 ប្រភេទ Delta ដែលមានការរីករាលដាលយ៉ាងងាយស្រួល ព្រមទាំងការបង្ហាញខ្លួននៃមេរោគប្រភេទ Omicron នោះ ការពាក់ម៉ាស់ពេលនៅខាងក្នុងអគារគឺជាការចាំបាច់ណាស់ដើម្បីកាត់បន្ថយការរីករាលដាលនៃជំងឺ COVID-19 នៅក្នុងសហគមន៍ ដោយមិនគិតពីស្ថានភាពនៃការចាក់ថ្នាំបង្ការឡើយ។ មេរោគប្រភេទ Delta និងមេរោគប្រភេទ Omicron នៃជំងឺ COVID-19 រីករាលដាលយ៉ាងងាយស្រួលជាងប្រភេទមេរោគផ្សេងទៀត ដែលបានរាលត្បាតនៅក្នុងខោនធី Los Angeles (LAC) នាពេលកន្លងមក។

យោងតាមរបាយការណ៍ដែលបានចុះផ្សាយ កត្តាដែលបង្កឱ្យការប្រឈមនឹងហានិភ័យនៃការឆ្លងមេរោគកើនឡើង រួមទាំងការចម្លងមេរោគទៅមនុស្សដែលឋិតនៅឆ្ងាយពីគ្នាលើសពី 6 ហ្វីតក៏ដោយ រួមមាន៖

- **ទីតាំងបិទជិតដោយមានខ្យល់បក់ចេញចូល ឬប្រព័ន្ធខ្យល់មិនគ្រប់គ្រាន់** ដែលអនុញ្ញាតឱ្យមានការប្រមូលផ្តុំវត្ថុរាវតាមផ្លូវដង្ហើម ជាពិសេសដំណក់ទឹកតូចៗ និងភាគល្អិតនៃដង្ហើមនៅក្នុងអាកាស។
- **ការកើនឡើងនៃការបញ្ចេញសារធាតុរាវតាមផ្លូវដង្ហើម** ដែលអាចកើតឡើងនៅពេលដែលអ្នកអាចចម្លងមេរោគបាននោះ ចូលរួមក្នុងសកម្មភាពដែលបញ្ចេញកម្លាំង ឬបង្កើនសំឡេងរបស់ពួកគេ (ឧទាហរណ៍ ការធ្វើលំហាត់ប្រាណ ការស្រែក ការច្រៀង)។
- **ការប៉ះពាល់រយៈពេលយូរ**ទៅនឹងស្ថានភាពដែលមានដូចចំណុចទាំងនេះ។

មានការណែនាំយ៉ាងម៉ឺងម៉ាត់ថា រាល់សកម្មភាពកីឡាធ្វើឡើងនៅខាងក្រៅអគារ ព្រោះហានិភ័យនៃការរីករាលដាលស្ថិតនៅកម្រិតទាបដោយសារតែនៅទីនោះមានខ្យល់បក់ចេញចូលល្អជាងនៅខាងក្នុងអគារ។

ខាងក្រោមនេះជាសេចក្តីសង្ខេបនៃតម្រូវការចាំបាច់ និងគំរូអនុវត្តល្អៗបំផុតសម្រាប់សម្ព័ន្ធកីឡាយុវជន (youth sports leagues) (រួមបញ្ចូលទាំងក្រុមកីឡាតាមសាលារៀនផងដែរ) ដើម្បីបង្កើនសុវត្ថិភាពសម្រាប់អ្នកចូលរួម គ្រូបង្វឹក អាជ្ញាកណ្តាល និងសហគមន៍របស់ពួកគេ និងដើម្បីកាត់បន្ថយហានិភ័យនៃការចម្លងជំងឺ COVID-19 នៅក្នុងក្រុមយុវជន និងរវាងក្រុមក្នុងអំឡុងពេលប្រកួត។ ដោយមានការលើកលែងតែសម្រាប់តម្រូវការនៃការធ្វើតេស្ត តម្រូវការខាងក្រោមទាំងនេះ អនុវត្តតែចំពោះក្រុមនិងសកម្មភាពកីឡាដែលមានមូលដ្ឋាននៅខោនធី LA និងមិនមែនសម្រាប់ក្រុមឬកីឡាករដែលស្ថិតក្រោមដែនយុត្តាធិការរបស់តំបន់ផ្សេង ហើយចូលមកប្រកួតក្នុងខោនធី LA ឡើយ។

ការធ្វើតេស្តពិនិត្យតាមដានជាប្រចាំសម្រាប់ក្រុម ឬសម្ព័ន្ធដែលមានមូលដ្ឋាននៅខោនធី LA ត្រូវបានតម្រូវជាចាំបាច់ ដូចដែលបានពិពណ៌នាខាងក្រោម ដោយសន្មតថាមានសមត្ថភាពធ្វើតេស្ត និងមានសម្ភារៈផ្គត់ផ្គង់គ្រប់គ្រាន់សម្រាប់ការធ្វើរោគវិនិច្ឆ័យនៃជំងឺ COVID-19 នេះ។ តម្រូវការចាំបាច់នៃការធ្វើតេស្តពិនិត្យតាមដានខាងក្រោមអាចត្រូវបានកែប្រែ ដោយផ្អែកលើការអាចរកបាន និងការអាចទទួលការធ្វើតេស្តបាន។ លើសពីនេះទៀត តម្រូវការចាំបាច់ទាំងនេះនៅតែមានប្រសិទ្ធិភាព ដរាបណានាយកដ្ឋានសុខភាពសាធារណៈនៃខោនធី Los Angeles (LACDPH) រាយការណ៍ថាមានអត្រានៃការចម្លងក្នុងសហគមន៍កម្រិតខ្ពស់ ឬកម្រិតគួរឱ្យកត់សម្គាល់ ហើយនឹងត្រូវធ្វើការវាយតម្លៃឡើងវិញនៅពេលការចម្លងក្នុងសហគមន៍ស្ថិតនៅកម្រិតមធ្យម ឬកម្រិតទាប។

បន្ថែមពីលើព័ត៌មាននេះ សូមចងចាំថា៖

- ☐ សម្ព័ន្ធកីឡាយុវជនត្រូវតែអនុវត្តតាម សេចក្តីបង្គាប់របស់មន្ត្រីសុខាភិបាល របស់ខោនធី Los Angeles និង ការណែនាំពីផែនការគ្រប់គ្រងការប៉ះពាល់នឹងមេរោគ COVID-19 សម្រាប់កម្មវិធីកីឡាកម្សាន្តរបស់យុវជនរបស់ខោនធី Los Angeles។
- ☐ សម្ព័ន្ធកីឡាយុវជនដែលជួលគ្រូបង្វឹកឬបុគ្គលិកជំនួយផ្សេងទៀតក៏ត្រូវប្រកាន់ខ្ជាប់នូវ បទដ្ឋានបណ្តោះអាសន្នបន្ទាន់នៃការបង្ការជំងឺ COVID-19 (ETS) របស់ CAL/OSHA។
- ☐ សម្ព័ន្ធកីឡាយុវជនដែលមានប្រតិបត្តិការលក់អាហារសម្រន់ គួរតែពិនិត្យឡើងវិញនិងអនុវត្តតាម គំរូអនុវត្តល្អបំផុតរបស់ LACDPH សម្រាប់សេវាកម្មម្ហូបអាហារនិង ភេសជ្ជៈ។

| |
|---|
| **សូមប្រាកដថាបានអាននិងអនុវត្តតាម ការណែនាំទូទៅសម្រាប់ម្ចាស់អាជីវកម្ម**។ គំរូអនុវត្តល្អបំផុតមានគោលបំណងបំពេញបន្ថែមទៅលើសេចក្តីណែនាំទូទៅ។ |

## អនុវត្តតាមច្បាប់នៃការពាក់ម៉ាស់ សម្រាប់អ្នកចូលរួម គ្រូបង្វឹក បុគ្គលិក និងអ្នកទស្សនាទាំងឡាយ

- ☐ **ច្បាប់នៃការពាក់ម៉ាស់ផ្អែកលើទីតាំង។** ការពាក់ម៉ាស់កាត់បន្ថយការរីករាលដាលនៃមេរោគ SARS-CoV-2 ដែលជាមេរោគដែលបង្កឱ្យមានជំងឺ COVID-19។ នៅតាមទីតាំងនៅខាងក្រៅអគារដែលមានចំនួនមនុស្សតិចជាង 5,000 នាក់ មានការណែនាំ ប៉ុន្តែមិនតម្រូវជាចាំបាច់ទេ ឱ្យទស្សនិកជនដែលមានទំនាក់ទំនងឬការប៉ះពាល់ជិតស្និទ្ធជាមួយអ្នកដទៃត្រូវពាក់ម៉ាស់ ដោយមិនគិតពីស្ថានភាពនៃការចាក់ថ្នាំបង្ការឡើយ។ នៅតាមទីតាំងខាងក្រៅអគារ គ្រូបង្វឹក បុគ្គលិក អ្នកស្ម័គ្រចិត្ត អាជ្ញាកណ្តាល និងក្រុមការងារខាងកីឡាទាំងអស់ត្រូវតែពាក់ម៉ាស់គ្រប់ពេលវេលា នៅពេលធ្វើការជាមួយក្រុមនៅតាមទីតាំងផ្សេងៗ ដែលមិនអាចអនុវត្តការរក្សាគម្លាតបាន និង

ដោយមិនគិតពីស្ថានភាពនៃការចាក់ថ្នាំបង្ការឡើយ។ នៅក្នុងទីតាំងខាងក្នុងអគារទាំងអស់ គ្រូបង្វឹក បុគ្គលិក អ្នកស្ម័គ្រចិត្ត អាជ្ញាកណ្តាល ក្រុមការងារខាងកីឡា និងអ្នកទស្សនាត្រូវតែពាក់ម៉ាស់គ្រប់ពេលវេលា ដោយមិនគិតពីស្ថានភាពនៃការចាក់ថ្នាំបង្ការឡើយ។

- ❑ **អ្នកចូលរួម៖** តម្រូវចាំបាច់ឱ្យអ្នកចូលរួមទាំងអស់ យកម៉ាស់តាមខ្លួន និងពាក់ម៉ាស់ ដោយមិនគិតពីស្ថានភាពចាក់ថ្នាំបង្ការឡើយ។ តម្រូវឱ្យពាក់ម៉ាស់ជានិច្ចពេលនៅខាងក្នុងអគារ នៅពេលដែលអ្នកចូលរួមមិនកំពុង អនុវត្តការហាត់សម ពង្រឹងសមត្ថភាព ប្រកួតប្រជែង ឬសម្តែងយ៉ាងសកម្មនោះទេ។ ម៉ាស់ក៏ត្រូវបានតម្រូវចាំបាច់ខណៈពេលឈរមើលពីខាងក្រៅការប្រកួត នៅក្នុងពេលការប្រជុំក្រុម និងនៅក្នុងបន្ទប់ដាក់សម្ភារៈនិងបន្ទប់ហាត់លើកទម្ងន់។ នៅពេលកំពុងអនុវត្តការហាត់សម ពង្រឹងសមត្ថភាព ឬប្រកួតប្រជែងក្នុងកីឡាដែលរៀបចំឡើងនៅខាងក្នុងអគារយ៉ាងសកម្មនោះ អ្នកចូលរួមទាំងឡាយតម្រូវចាំបាច់ឱ្យពាក់ម៉ាស់ តាមដែលអាចអនុវត្តទៅបាន។ នៅពេលកំពុងអនុវត្តការហាត់សម ពង្រឹងសមត្ថភាព ឬប្រកួតប្រជែងយ៉ាងសកម្មក្នុងកីឡាដែលរៀបចំឡើងនៅខាងក្រៅអគារដែលមានកម្រិតហានិភ័យមធ្យមនិងខ្ពស់ហើយដែលការរក្សាគម្លាតមិនអាចអនុវត្តបាននោះ តម្រូវចាំបាច់ឱ្យអ្នកចូលពាក់ម៉ាស់តាមដែលអាចអនុវត្តបាន។ ជំរុញឱ្យអ្នកចូលរួមយកម៉ាស់តាមខ្លួនឱ្យបានច្រើនជាងមួយក្នុងពេលហាត់សម ឬពេលប្រកួត ក្នុងករណីដែលម៉ាស់របស់ពួកគេសើម ឬប្រឡាក់ក្នុងអំឡុងពេលប្រកួតនោះ។ ម៉ាស់ណាដែលប្រឡាក់ញើសជោកគួរតែផ្លាស់ប្តូរភ្លាមៗ។

  យោងតាមបណ្ឌិតសភាគ្រូពេទ្យជំនាញខាងកុមារអាមេរិក (American Academy of Pediatrics) "មនុស្សភាគច្រើនដែលបានពាក់ម៉ាស់ក្នុងពេលធ្វើលំហាត់ប្រាណ អាចអត់ធន់នឹងវាបាន។" ទោះជាយ៉ាងណាក៏ដោយ អាចដោះម៉ាស់ចេញក្នុងកាលៈទេសៈដូចខាងក្រោម។

  - *ពេលកំពុងពិសាអាហារ និងភេសជ្ជៈ។* អ្នកចូលរួមអាចដោះម៉ាស់របស់ពួកគេចេញជាបណ្តោះអាសន្នបានដើម្បីពិសាអាហារ ឬភេសជ្ជៈ។ នៅពេលដែលអ្នកចូលរួមកំពុងពិសាអាហារ ឬភេសជ្ជៈយ៉ាងសកម្ម ពួកគេគួរតែត្រូវបានជម្រុញឱ្យរក្សាគម្លាត 6 ហ្វីតពីអ្នកដទៃ ដើម្បីកាត់បន្ថយហានិភ័យនៃការប៉ះពាល់នឹងមេរោគប្រសិនបើនរណាម្នាក់មានឆ្លងមេរោគ។
  - *ចំពោះកីឡាក្នុងទឹក។* អ្នកចូលរួមដែលកំពុងលេងកីឡាក្នុងទឹក ដូចជាហែលទឹក កីឡាគប់បាល់ក្នុងទឹក (water polo) ឬកីឡាលោតទឹក អាចដោះម៉ាស់ចេញបាននៅពេលពួកគេកំពុងនៅ និងមុនពេលមុជទៅក្នុងទឹក។ ម៉ាស់ត្រូវតែពាក់ នៅពេលដែលអ្នកចូលរួមមិននៅក្នុងទឹក។
  - *ចំពោះកាយសម្ព័ន្ធ (gymnastics)។* កីឡាករកាយសម្ព័ន្ធ (gymnasts) ដែលកំពុងហាត់សម/សម្តែងយ៉ាងសកម្មនៅលើឧបករណ៍ហាត់កាយសម្ព័ន្ធ អាចដោះម៉ាស់របស់ពួកគេចេញបាន ដោយសារតែតាមទ្រឹស្តីហានិភ័យដែលអាចកើតមានថា ម៉ាស់អាចទាក់ជាមួយវត្ថុផ្សេងៗ ហើយអាចបង្ការជាគ្រោះថ្នាក់ថប់ដង្ហើម ឬប៉ះពាល់ដល់ចក្ខុវិស័យដោយចៃដន្យ។ ការពាក់ម៉ាស់ជាតម្រូវចាំបាច់សម្រាប់ការហាត់លើកម្រាល (floor routines) ហើយនៅពេលដែលកីឡាករកាយសម្ព័ន្ធមិនកំពុងហាត់សម/សម្តែងយ៉ាងសកម្ម នៅលើឧបករណ៍ហាត់កាយសម្ព័ន្ធនោះ។
  - *ចំពោះការសម្តែងការគាំទ្រជាការប្រកួត (competitive cheerleading)។* ក្រុមសម្តែងការគាំទ្រដែលកំពុងសម្តែង/ហាត់សមក្បាច់ប្រកួតយ៉ាងសកម្ម ដែលមានដូចជាការផ្តួលខ្លួន ហក់លោត ឬហោះឡើងលើ អាចដោះម៉ាស់របស់ពួកគេចេញបាន ដោយសារតែតាមទ្រឹស្តីហានិភ័យដែលអាចកើតមានថា ម៉ាស់អាចទាក់ជាមួយវត្ថុផ្សេងៗ ហើយអាចបង្ការជាគ្រោះថ្នាក់ថប់ដង្ហើម ឬប៉ះពាល់ដល់ចក្ខុវិស័យដោយចៃដន្យ។
  - *ចំពោះកីឡាបោកចំបាប់។* ក្នុងអំឡុងពេលបោកចំបាប់ដោយប៉ះពាល់ផ្ទាល់ ការពាក់ម៉ាស់អាចក្លាយជាគ្រោះថ្នាក់ថប់ដង្ហើម និងមិនត្រូវបានជម្រុញឱ្យពាក់នោះទេ លុះត្រាតែមានគ្រូបង្វឹកដែលជាមនុស្សពេញវ័យ ឬក្រុមការងារខាងកីឡាម្នាក់កំពុងតាមដានយ៉ាងជិតដល់សម្រាប់គោលបំណងសុវត្ថិភាព។

- ❑ **ទស្សនិកជន៖** នៅពេលដែលស្ថិតនៅខាងក្នុងអគារ ត្រូវតម្រូវចាំបាច់ឱ្យទស្សនិកជនទាំងអស់ យកម៉ាស់តាមខ្លួន និងពាក់ម៉ាស់ ដោយមិនគិតពីស្ថានភាពនៃការចាក់ថ្នាំបង្ការឡើយ។ រៀបចំម៉ាស់សម្រាប់ការប្រើប្រាស់ជូនអ្នកដែលមកដល់ទីតាំងដោយមិនមានម៉ាស់។ នៅពេលស្ថិតនៅខាងក្រៅអគារ ការពាក់ម៉ាស់ត្រូវបានណែនាំសម្រាប់ពេលនៅទីតាំង និងកន្លែងដែលមានមនុស្សច្រើនកុះករ ព្រមទាំងពេលស្ថិតនៅក្នុងចំណោមទស្សនិកជននៅព្រឹត្តិការណ៍កីឡាទាំងឡាយ ដែលការរក្សាគម្លាតមិនអនុវត្តតាមបាន ឬមិនអាចធ្វើទៅបាន។ ចំពោះព្រឹត្តិការណ៍កីឡានៅខាងក្រៅអគារដែលមានការចូលរួមពីមនុស្សចាប់ពី 5,000 នាក់ឡើងទៅ ការពាក់ម៉ាស់ជាទូទៅត្រូវបានតម្រូវជាចាំបាច់សម្រាប់ទស្សនិកជននិងបុគ្គលិកទាំងអស់ លើកលែងតែពេលវេលាខ្លីៗមានកំណត់នៅពេលទទួលទានអាហារ ឬភេសជ្ជៈប៉ុណ្ណោះ។

- ❑ **គ្រូបង្វឹក៖** នៅពេលដែលស្ថិតនៅខាងក្នុងអគារ ត្រូវតម្រូវចាំបាច់ឱ្យគ្រូបង្វឹកទាំងអស់ យកម៉ាស់តាមខ្លួន និងពាក់ម៉ាស់ ដោយមិនគិតពីស្ថានភាពនៃការចាក់ថ្នាំបង្ការឡើយ។ នៅពេលនៅខាងក្រៅអគារ តម្រូវឱ្យគ្រូបង្វឹកទាំងអស់ដែលកំពុងបង្ហាត់ក្រុមកីឡាដែលមានកម្រិតហានិភ័យមធ្យមនិងខ្ពស់ ដែលមិនអាចរក្សាគម្លាតបាន ត្រូវយក ម៉ាស់តាមខ្លួននិងពាក់ម៉ាស់ ដោយមិនគិតពីស្ថានភាពនៃការចាក់ថ្នាំបង្ការឡើយ។ គ្រូបង្វឹកត្រូវតែពាក់ម៉ាស់ សូម្បីតែពេលចូលរួមក្នុងសកម្មភាពដែលប្រើកម្លាំងរាងកាយខ្លាំង នៅពេលដែលស្ថិតនៅខាងក្នុងអគារ។
- ❑ **អាជ្ញាកណ្តាល និងក្រុមការងារខាងកីឡាផ្សេងៗទៀត៖** នៅពេលដែលស្ថិតនៅខាងក្នុងអគារ ត្រូវតម្រូវចាំបាច់ឱ្យអាជ្ញាកណ្តាល និងក្រុមការងារខាងកីឡាទាំងអស់យកម៉ាស់តាមខ្លួននិងពាក់ម៉ាស់គ្រប់ពេលវេលា ដោយមិនគិតពីស្ថានភាពនៃការចាក់ថ្នាំបង្ការឡើយ។ នៅពេលនៅខាងក្រៅអគារ តម្រូវឱ្យអាជ្ញាកណ្តាលនិងក្រុមការងារខាងកីឡាទាំងអស់ដែលកំពុងធ្វើការជាមួយក្រុមកីឡាដែលមានកម្រិតហានិភ័យមធ្យមនិងខ្ពស់ ហើយដែលមិនអាចរក្សាគម្លាតបាន ត្រូវយកម៉ាស់តាមខ្លួននិងពាក់ម៉ាស់គ្រប់ពេលវេលា ដោយមិនគិតពីស្ថានភាពនៃការចាក់ថ្នាំបង្ការឡើយ។
- ❑ **បុគ្គលិក៖** ប្រសិនបើសម្ព័ន្ធកីឡាយុវជនមានជួលគ្រូបង្វឹក ឬបុគ្គលិកជំនួយផ្សេងទៀត សូមកត់សម្គាល់ថា តាមការស្នើសុំ កន្លែងធ្វើការតម្រូវឱ្យផ្តល់ដល់បុគ្គលិក ដែលមិនបានចាក់ថ្នាំបង្ការពេញលេញប្រឆាំងនឹងជំងឺ COVID-19 ដែលកំពុងធ្វើការនៅទីតាំងខាងក្នុងអគារនានា និងក្នុងយានយន្តរួមគ្នា នូវឧបករណ៍ជំនួយការដកដង្ហើមដែលទំហំត្រឹមត្រូវសម្រាប់ការប្រើប្រាស់ដោយស្ម័គ្រចិត្ត ព្រមទាំងផ្តល់ការណែនាំជាមូលដ្ឋានអំពីរបៀបនៃការបិទផ្ជិតឱ្យបានល្អ។ ឧបករណ៍ជំនួយការដកដង្ហើមត្រូវតែផ្លាស់ប្តូរ ប្រសិនបើវាមានការខូចខាត ខូចទ្រង់ទ្រាយ កខ្វក់ ឬពិបាកក្នុងការដកដង្ហើម។ សម្រាប់ព័ត៌មានបន្ថែមអំពីឧបករណ៍ការពារផ្ទាល់ខ្លួន (PPE) ដែលឥតគិតថ្លៃនិងចំណាយទាបសម្រាប់អាជីវកម្ម និងអង្គភាពផ្សេងៗ សូមចូលទៅមើល៖ http://publichealth.lacounty.gov/docs/FreeAndLowCostPPE.pdf។
- ❑ បុគ្គលិកដែលធ្វើការនៅក្នុងទីកន្លែងមួយ ដែលពួកគេមានទំនាក់ទំនងឬការប៉ះពាល់ជិតស្និទ្ធជាមួយមនុស្សដទៃទៀតដែលប្រហែលជាមិនបានចាក់ថ្នាំបង្ការពេញលេញ គួរជម្រុញឱ្យពួកគេពាក់ម៉ាស់ការពារដែលមានកម្រិតខ្ពស់ជាងមុន ដូចជា "ការពាក់ម៉ាស់ពីរជាន់" (ពាក់ម៉ាស់ក្រណាត់នៅពីលើម៉ាស់វះកាត់) ឬប្រើឧបករណ៍ជំនួយការដកដង្ហើម។ នេះមានសារៈសំខាន់ខ្លាំងណាស់ ប្រសិនបើបុគ្គលិកមិនបានចាក់ថ្នាំបង្ការពេញលេញ ឬបានចាក់ថ្នាំបង្ការពេញលេញ ប៉ុន្តែមានបញ្ហាសុខភាពមិនបង្ហាញមុខដែលធ្វើឱ្យពួកគេប្រឈមនឹងហានិភ័យខ្ពស់ ហើយកំពុងធ្វើការនៅទីតាំងខាងក្នុងអគារ ទីតាំងនៅខាងក្រៅអគារដែលមានមនុស្សច្រើនកុះករ ឬក៏ស្ថិតនៅខាងក្នុងយានយន្តរួមគ្នា។

## ចាក់ថ្នាំបង្ការ

- ❑ សិស្សដែលជាអត្តពលិក (អ្នកលេងកីឡាឱ្យសាលារៀន) ដែលមានអាយុចាប់ពី 5 ឆ្នាំឡើងទៅ គ្រូបង្វឹក និងបុគ្គលិកក្រុមកីឡាទាំងអស់ ត្រូវបានណែនាំយ៉ាងម៉ឺងម៉ាត់ថា ត្រូវតែចាក់ថ្នាំបង្ការឱ្យបានពេញលេញ។ ការចាក់ថ្នាំបង្ការប្រឆាំងនឹងមេរោគដែលបង្កឱ្យមានជំងឺ COVID-19 គឺមានផ្តល់ជូនសម្រាប់មនុស្សគ្រប់រូបដែលមានអាយុចាប់ពី 5 ឆ្នាំឡើងទៅ។ ការចាក់ថ្នាំបង្ការគឺជាវិធីសាស្ត្រចម្បងដើម្បីកាត់បន្ថយបន្ទុកនៃជំងឺ COVID-19 និងការពារសមាជិកសហគមន៍ទាំងអស់។ ពេលអត្តពលិក និងបុគ្គលិកទាំងអស់នៅក្នុងសម្ព័ន្ធកីឡាយុវជនរបស់អ្នកបានចាក់ថ្នាំបង្ការពេញលេញ និងទទួលចាក់ដូសជំរុញ កាន់តែឆាប់តាមដែលពួកគេមានសិទ្ធិទទួលចាក់នោះ នឹងកាត់បន្ថយហានិភ័យនៃការឆ្លងមេរោគក្នុងចំណោមមិត្តរួមក្រុម និងរវាងក្រុម ហើយនឹងផ្តល់នូវការការពារយ៉ាងល្អបំផុតដើម្បីប្រឆាំងនឹងការធ្លាក់ខ្លួនឈឺធ្ងន់ធ្ងរ ការសម្រាកព្យាបាលនៅមន្ទីរពេទ្យ និងការស្លាប់ផងដែរ។ វាក៏នឹងកាត់បន្ថយការរំខានដល់សកម្មភាពរបស់ក្រុមផងដែរ ព្រោះបុគ្គលដែលស្ថានភាពនៃការចាក់ថ្នាំបង្ការគឺគ្រប់លក្ខណៈនិងទាន់ពេលវេលា[1] មិនចាំបាច់តម្រូវឱ្យធ្វើចត្តាឡីស័កទេ ប្រសិនបើពួកគេជាអ្នកដែលមានទំនាក់ទំនងជិតស្និទ្ធទៅនឹងករណីនៃជំងឺ COVID-19 ដរាបណាពួកគេនៅតែមិនមានរោគសញ្ញា និងបន្តធ្វើតេស្តទទួលបានលទ្ធផលថាអវិជ្ជមាន។
- ❑ សម្ព័ន្ធកីឡាយុវជន អ្នករៀបចំចាត់ចែងក្រុមកីឡា ឬគ្រូបង្វឹក គួរតែរក្សាកំណត់ត្រានៃស្ថានភាពចាក់ថ្នាំបង្ការរបស់អត្តពលិកនិងបុគ្គលិក/គ្រូបង្វឹក/អ្នកស្ម័គ្រចិត្ត និងការយល់ព្រមនឹងការធ្វើតេស្តរកមេរោគ COVID-19

---

[1] ស្ថានភាពនៃការចាក់ថ្នាំបង្ការដែលគ្រប់លក្ខណៈនិងទាន់ពេលវេលាសំដៅទៅលើការទទួលចាក់ដូសជំរុញនៃថ្នាំបង្ការជំងឺ COVID-19 នៅពេលដែលមានសិទ្ធិទទួលចាក់ ឬបានបញ្ចប់ការចាក់លំដាប់ដំបូងនៃថ្នាំបង្ការ COVID-19 ប្រសិនបើមិនទាន់មានសិទ្ធិទទួលចាក់ដូសជំរុញនៅឡើយ។ សូមមើល សេចក្តីសង្ខេបអំពីសិទ្ធិទទួលចាក់ថ្នាំបង្ការ។

ប្រចាំសប្តាហ៍។ ពួកគេមិនចាំបាច់រក្សាទុកច្បាប់ចម្លងភស្តុតាងនៃការចាក់ថ្នាំបង្ការពេញលេញ ឬច្បាប់ចម្លងនៃលទ្ធផលតេស្តនោះទេ។

## ពិនិត្យរករោគសញ្ញា ហើយដាក់ឱ្យនៅដាច់ដោយឡែក

- ❑ សូមឱ្យអ្នកចូលរួម និងក្រុមគ្រួសារធ្វើការពិនិត្យរករោគសញ្ញានៃជំងឺ COVID-19 ដោយខ្លួនឯង មុនពេលចូលរួមសកម្មភាពកីឡារបស់យុវជន។
- ❑ សូមបិទ ផ្លាកសញ្ញា ដើម្បីរំលឹកដល់មនុស្សគ្រប់គ្នាដែលចូលក្នុងទីតាំងរបស់អ្នក ដែលថាពួកគេមិនគួរចូលក្នុងកន្លែងនេះទេ ប្រសិនបើពួកគេមានរោគសញ្ញានៃជំងឺ COVID-19 ឬប្រសិនបើពួកគេស្ថិតនៅក្រោមបទបញ្ជាឱ្យដាក់នៅដាច់ដោយឡែក ឬឱ្យធ្វើចត្តាឡីស័ក។
- ❑ កម្មវិធីកីឡាសម្រាប់យុវជនត្រូវតែដកចេញ ឬដាក់អ្នកចូលរួម គ្រូបង្វឹក ឬទស្សនិកជនណា ដែលមានរោគសញ្ញានៃជំងឺ COVID-19 ឱ្យនៅដាច់ដោយឡែក។
  - ចាត់វិធានការណ៍ដើម្បីដាក់អ្នកចូលរួមដែលចាប់ផ្តើមមានរោគសញ្ញានៃជំងឺ COVID-19 ឱ្យនៅដាច់ដោយឡែក ក្នុងអំឡុងពេលមានសកម្មភាពកីឡាយុវជន ពីអ្នកចូលរួម គ្រូបង្វឹក និងទស្សនិកជនដទៃទៀត។
  - ជូនដំណឹងដល់មន្ត្រីរបស់ LACDPH បុគ្គលិក និងក្រុមគ្រួសារទាំងអស់ជាបន្ទាន់ ចំពោះករណីមានជំងឺ COVID-19 ច្បាស់លាស់នានា។
  - តម្រូវចាំបាច់ឱ្យមានការផ្អាកនៃសកម្មភាពក្រុមទាំងអស់ចំនួនយ៉ាងហោចណាស់ 7 ថ្ងៃ និងឱ្យមានការយល់ព្រមដោយ DPH មុនពេលបន្តសកម្មភាព ចំពោះក្រុមកីឡាយុវជនណាមួយដែលមានការផ្ទុះឡើងនូវករណីដែលទាក់ទងនឹងការរីករាលដាលនៃជំងឺចំនួន 4 ករណីឡើងទៅក្នុងអំឡុងពេល 14 ថ្ងៃ។ ការពង្រឹងសមត្ថភាព ឬកសាងជំនាញផ្ទាល់ខ្លួនអាចបន្តក្នុងអំឡុងពេលផ្អាកនេះបានដរាបណាមនុស្សគ្រប់គ្នានៅតាមក្រុមគោរពយ៉ាងពេញលេញទៅនឹងសេចក្តីបង្គាប់ទាំងឡាយនៃការដាក់ឱ្យនៅដាច់ដោយឡែក ឬការឱ្យធ្វើចត្តាឡីស័កណាមួយ ដែលត្រូវអនុវត្ត។

## កាត់បន្ថយការប្រមូលផ្តុំគ្នាច្រើនកុះករ ជាពិសេសនៅខាងក្នុងអគារ

- ❑ ប្រសិនបើអាចធ្វើទៅបាន ចូររៀបចំសកម្មភាពកីឡាយុវជននៅខាងក្រៅអគារដែលហានិភ័យនៃការឆ្លងជំងឺ COVID-19 មានកម្រិតទាបច្រើន។
- ❑ ប្រសិនបើសកម្មភាពកីឡាយុវជនត្រូវតែធ្វើឡើងនៅខាងក្នុងអគារ សូមចាត់វិធានការណ៍ដើម្បីកាត់បន្ថយចំនួនអ្នកចូលរួម គ្រូបង្វឹក និងទស្សនិកជន នៅបរិវេណទីតាំងខាងក្នុងអគារណាមួយ។
- ❑ ការរក្សាគម្លាតរាងកាយគឺជាគំរូអនុវត្តល្អបំផុតសម្រាប់ការគ្រប់គ្រងការឆ្លងមេរោគ ដែលអាចត្រូវបានអនុវត្តជាស្រទាប់សុវត្ថិភាពបន្ថែមដើម្បីកាត់បន្ថយការរីករាលដាលនៃជំងឺ COVID-19។ ក្នុងអំឡុងពេលអនុវត្ត សូមជំរុញឱ្យមានសកម្មភាពដែលមិនសូវពាក់ព័ន្ធនឹងការប៉ះពាល់គ្នាដោយផ្ទាល់រយៈពេលយូរ រវាងមនុស្សម្នាក់ទៅមនុស្សម្នាក់ រវាងអ្នកចូលរួម និង/ឬក្រុមគ្រូបង្វឹក ហើយចូរដាក់កំណត់លើសកម្មភាពបែបនេះ នៅទីតាំងខាងក្នុងអគារ។ ផ្ទុយទៅវិញ ចូរពិចារណាផ្តោតលើសកម្មភាពបង្កើតជំនាញ។
- ❑ ចូរកំណត់ចំនួនអ្នកចូលរួមដែលចូលប្រើបន្ទប់ទឹក ឬបន្ទប់ប្តូរសំលៀកបំពាក់នៅក្នុងពេលណាមួយ។
- ❑ ព្រឹត្តិការណ៍ក្នុងក្រុមដែលមិនទាក់ទងនឹងអត្តពលកម្ម ដូចជាការទទួលទានអាហារពេលល្ងាចជាក្រុម ឬសកម្មភាពសង្គមផ្សេងៗទៀត គួរតែអាចរៀបចំឡើងបាន នៅពេលដែលអាចធ្វើទៅបាន នៅខាងក្រៅអគារ ដោយមានការរក្សាគម្លាតពីគ្នាបាន។

### ការធ្វើតេស្តត្រួតពិនិត្យរកមេរោគ COVID-19 ជាប្រចាំ

មេរោគដែលបង្កឱ្យមានជំងឺ COVID-19 អាចឆ្លងដល់សមាជិកណាម្នាក់នៃសម្ព័ន្ធកីឡាយុវជន សូម្បីតែសមាជិកដែលបានចាក់ថ្នាំបង្ការពេញលេញ[2] ហើយក៏ដោយ ប៉ុន្តែវាកាន់តែទំនងជាឆ្លងទៅអ្នកដែលមិនបានចាក់ថ្នាំបង្ការជាង។ មនុស្ស

---

[2] ទាំងនេះគឺអាចទទួលយកបានជាភស្តុតាងនៃ "ការចាក់ថ្នាំបង្ការពេញលេញ"៖ 1) ប័ណ្ណសម្គាល់ខ្លួនអ្នកចូលរួមដែលមានរូបថត និង 2) កាតចាក់ថ្នាំបង្ការរបស់ពួកគេ (ដែលរួមបញ្ចូលទាំងឈ្មោះអ្នកដែលបានចាក់ថ្នាំបង្ការ ប្រភេទថ្នាំបង្ការ COVID-19 ដែលបានផ្តល់ជូន និងកាលបរិច្ឆេទនៃការផ្តល់ជូនដូសចុងក្រោយ) ឬរូបថតនៃកាតចាក់ថ្នាំបង្ការជាឯកសារដាច់ដោយឡែក ឬរូបថតនៃកាតចាក់ថ្នាំបង្ការរបស់អ្នកចូលរួមដែលត្រូវបានរក្សាទុកនៅក្នុងទូរស័ព្ទឬឧបករណ៍អេឡិចត្រូនិក ឬឯកសារនៃការចាក់ថ្នាំបង្ការពេញលេញដែលបាន មកពីអ្នកផ្តល់សេវាថែទាំសុខភាព (ដែលរួមមានឈ្មោះ

ដែលផ្ទុកមេរោគអាចចម្លងមេរោគនេះទៅអ្នកដទៃបានផងដែរ។ វិធីសាស្រ្តមួយដើម្បីកំណត់អត្តសញ្ញាណបុគ្គលដែលឆ្លងមេរោគឱ្យបានត្រឹមត្រូវ ហើយបន្ទាប់មកដាក់ពួកគេឱ្យនៅដាច់ដោយឡែកបានឆាប់រហ័សនោះ គឺដោយមាន ការធ្វើតេស្តតាមដានតាមពេលកំណត់ទៀងទាត់សម្រាប់ជំងឺ COVID-19 ដោយការធ្វើតេស្តរកហ្សែនមេរោគ ឬការធ្វើតេស្តពង្រីកអាស៊ីដនុយក្លេអ៊ិច (NAAT) ដូចជា ការធ្វើតេស្តរកទម្រង់មេរោគ (PCR) ឬការធ្វើតេស្តរកសារធាតុដែលបញ្ចូលក្នុងខ្លួនដើម្បីបង្កើតភាពស៊ាំ (Antigen, Ag)។ ការណែនាំនិងអនុសាសន៍ទូទៅអំពីការធ្វើតេស្ត រួមទាំងប្រភេទតេស្តដែលអាចរកបាន សូមចូលកាន់ទំព័រអំពី ព័ត៌មាននៃការធ្វើតេស្តសម្រាប់អ្នកជំងឺ របស់យើង។

- ❑ បុគ្គលដែលបានជាសះស្បើយពីជំងឺ COVID-19 ឬបានបញ្ចប់ការដាក់ឱ្យនៅដាច់ដោយឡែកដែលបានបញ្ជាក់ដោយមន្ទីរពិសោធន៍ក្នុងអំឡុងពេល 90 ថ្ងៃកន្លងមកនេះ មិនគួរដាក់បញ្ចូលក្នុងការធ្វើតេស្តពិនិត្យរកមេរោគ COVID-19 តាមពេលកំណត់នោះទេ ប្រសិនបើបុគ្គលនោះមិនមានរោគសញ្ញា។ ការពិនិត្យសម្រាប់បុគ្គលដែលមិនបានចាក់ថ្នាំបង្ការពេញលេញ ហើយដែលធ្លាប់បានឆ្លងជំងឺ COVID-19[3] គួរតែចាប់ផ្តើមរាប់ 90 ថ្ងៃ បន្ទាប់ពីថ្ងៃនៃការចេញរោគសញ្ញាដំបូង ឬចាប់ពីថ្ងៃនៃការប្រមូលការធ្វើតេស្តដែលទទួលលទ្ធផលថាវិជ្ជមានដំបូង (ប្រសិនបើពួកគេមិនមានរោគសញ្ញា)។
- ❑ នៅពេលណាដែលរកឃើញថា មានករណីឆ្លងមេរោគច្បាស់លាស់ត្រូវបានកំណត់អត្តសញ្ញាណនៅក្នុងក្រុមកីឡាយុវជនណាមួយរបស់អ្នក សូមអនុវត្តតាមការណែនាំដែលមាននៅក្នុង ផែនការគ្រប់គ្រងការប៉ះពាល់សម្រាប់កីឡាយុវជន និងធានាថា រាល់បុគ្គលដែលមានទំនាក់ទំនងជិតស្និទ្ធណា ដែលមិនបានទទួលការចាក់ថ្នាំបង្ការ ត្រូវដាក់ឱ្យធ្វើចត្តាឡីស័ក រួមទាំងបុគ្គលដែលមានទំនាក់ទំនងជិតស្និទ្ធណាដែលបានទទួលការចាក់ថ្នាំបង្ការហើយមានបង្ហាញនូវរោគសញ្ញា។
- ❑ សម្ព័ន្ធកីឡាយុវជន អ្នករៀបចំចាត់ចែងក្រុម ឬគ្រូបង្វឹក គួរតែរក្សាកំណត់ត្រានៃស្ថានភាពចាក់ថ្នាំបង្ការរបស់អត្តពលិក និងរបស់បុគ្គលិក/គ្រូបង្វឹក/អាជ្ញាកណ្តាល/អ្នកស្ម័គ្រចិត្តទាំងអស់ និងការយល់ព្រមនឹងការធ្វើតេស្តរកមេរោគ COVID-19 ប្រចាំសប្តាហ៍ ព្រមទាំងការធ្វើតេស្តណាមួយដែលបានធ្វើបន្ទាប់ពីបានប៉ះពាល់នឹងករណីជំងឺ COVID-19។ ពួកគេមិនចាំបាច់រក្សាទុកច្បាប់ចម្លងភស្តុតាងនៃការចាក់ថ្នាំបង្ការពេញលេញ ឬច្បាប់ចម្លងនៃលទ្ធផលតេស្តនោះទេ។

នាពេលបច្ចុប្បន្ននេះ ដោយមានការចម្លងក្នុងសហគមន៍មានកម្រិតខ្ពស់ ឬកម្រិតគួរឱ្យកត់សម្គាល់កំពុងកើតឡើងនៅក្នុងខោនធី Los Angeles តម្រូវការចាំបាច់នៃការធ្វើតេស្តដូចខាងក្រោម ត្រូវអនុវត្តចំពោះអត្តពលិក និងបុគ្គលិក/គ្រូបង្វឹក/អាជ្ញាកណ្តាល/អ្នកស្ម័គ្រចិត្តដែលចូលរួមទាំងអស់។ បុគ្គលដែលបង្ហាញភស្តុតាងថាស្ថានភាពនៃការចាក់ថ្នាំបង្ការគ្រប់លក្ខណៈនិងទាន់ពេលវេលារបស់ពួកគេ ប្រឆាំងនឹងជំងឺ COVID-19 ហើយទាំងមិនដែលកំពុងប្រកួតដោយមិនពាក់ម៉ាស់ ឬក៏មិនប្រកួតជាមួយមិត្តរួមក្រុមដែលមិនពាក់ម៉ាស់ពេលនៅខាងក្នុងអគារនោះ ឬដែលបានជាសះស្បើយពីជំងឺ COVID-19 ឬបានបញ្ចប់ការដាក់ឱ្យនៅដាច់ដោយឡែក ដែលបានបញ្ជាក់ដោយមន្ទីរពិសោធន៍ក្នុងអំឡុងពេល 90 ថ្ងៃកន្លងមកនេះ មិនគួរដាក់បញ្ចូលក្នុងការធ្វើតេស្តពិនិត្យតាមដានមេរោគ COVID-19 តាមពេលកំណត់នោះទេ ប្រសិនបើបុគ្គលនោះគ្មានរោគសញ្ញា។ ការពិនិត្យតាមដានសម្រាប់បុគ្គលដែលស្ថានភាពនៃការចាក់ថ្នាំបង្ការរបស់ពួកគេមិនគ្រប់លក្ខណៈនិងមិនទាន់ពេលវេលា ព្រមទាំងដែលធ្លាប់បានឆ្លងជំងឺ COVID-19 គួរចាប់ផ្តើម ឬចាប់ផ្តើមនូវការធ្វើតេស្តពិនិត្យរកមេរោគឡើងវិញក្នុងរយៈពេលចំនួន 90 ថ្ងៃ បន្ទាប់ពីថ្ងៃនៃការចេញរោគសញ្ញាដំបូង ឬចាប់ផ្តើមពីថ្ងៃនៃការប្រមូលការធ្វើតេស្តដែលទទួលលទ្ធផលថាវិជ្ជមានដំបូង។ សូមមើលតារាងខាងក្រោមសម្រាប់ឧទាហរណ៍នៃប្រភេទកីឡាដែលចាត់ចូលតាមចំណាត់ថ្នាក់នៃកម្រិតហានិភ័យផ្សេងៗគ្នា។

---

អ្នកដែលបានចាក់ថ្នាំបង្ការ និងបញ្ជាក់ថាអ្នកចូលរួមនោះបានចាក់ថ្នាំបង្ការជំងឺ COVID-19 ពេញលេញ)។ សម្រាប់គោលបំណងនៃពិធីការនេះ បុគ្គលនានាត្រូវបានចាត់ទុកថា “បានចាក់ថ្នាំបង្ការពេញលេញ” ប្រឆាំងមេរោគ COVID-19៖ 2 សប្តាហ៍ឡើងទៅ បន្ទាប់ពីការចាក់ដូសទីពីរនៃប្រភេទថ្នាំបង្ការជំងឺ COVID-19 របស់ពួកគេដែលមានលំដាប់ 2 ដូស រួមមានប្រភេទ Pfizer ឬប្រភេទ Moderna ឬ 2 សប្តាហ៍ឡើងទៅ បន្ទាប់ពីការចាក់ថ្នាំបង្ការជំងឺ COVID-19 ដែលមានតែមួយដូសដូចជាប្រភេទ Johnson & Johnson (J&J)/Janssen ឬក៏រយៈពេល 2 សប្តាហ៍ឡើងទៅ បន្ទាប់ពីបញ្ចប់ការចាក់តាមលំដាប់នៃថ្នាំបង្ការជំងឺ COVID-19 ណាដែលបានចុះបញ្ជីសម្រាប់ការប្រើប្រាស់ជាបន្ទាន់ដោយអង្គការសុខភាពពិភពលោក (WHO) (ឧទាហរណ៍ ប្រភេទ AstraZeneca/Oxford)។ សូមចូលទៅកាន់ គេហទំព័រ របស់ WHO សម្រាប់ព័ត៌មានបន្ថែមអំពីថ្នាំបង្ការជំងឺ COVID-19 ដែលត្រូវបានអនុញ្ញាតឱ្យប្រើដោយ WHO។

[3] ទាំងនេះគឺអាចទទួលយកបានជាភស្តុតាងនៃការឆ្លងជំងឺ COVID-19 ពីពេលមុន (លទ្ធផលធ្វើតេស្តរកមេរោគថាវិជ្ជមានពីពេលមុន) និងការបញ្ចប់ការដាក់ខ្លួនឱ្យនៅដាក់ដោយឡែកក្នុងអំឡុងពេល 90 ថ្ងៃចុងក្រោយ៖ ប័ណ្ណសម្គាល់ខ្លួនដែលមានរូបថត និងឯកសារចម្លងនៃការធ្វើតេស្តរកសារធាតុដែលបញ្ចូលក្នុងខ្លួនដើម្បីបង្កើតភាពស៊ាំ (antigen) នឹងជំងឺ COVID-19 ឬការធ្វើតេស្តរកទម្រង់មេរោគ (PCR) ទទួលលទ្ធផលថាវិជ្ជមានរបស់ពួកគេជាលក្ខណៈក្រដាស ឬលក្ខណៈឌីជីថលនៅលើទូរស័ព្ទឬឧបករណ៍អេឡិចត្រូនិចរបស់ពួកគេ ក្នុងចន្លោះពេល 90 ថ្ងៃចុងក្រោយ ប៉ុន្តែមិនមែនក្នុងចន្លោះពេល 10 ថ្ងៃចុងក្រោយទេ។ បុគ្គលនេះត្រូវតែបំពេញនូវ តម្រូវការដាក់ខ្លួនឱ្យនៅដាក់ដោយឡែក មុនពេលចូលរួមប្រកួត។

1. **កីឡានៅខាងក្នុងអគារដែលមានកម្រិតហានិភ័យមធ្យមឬខ្ពស់ សម្រាប់កុមារគ្រប់កម្រិតអាយុ ព្រមទាំងបុគ្គលិក/គ្រូបង្វឹក/អ្នកស្ម័គ្រចិត្ត។** តម្រូវឱ្យមានលទ្ធផលធ្វើតេស្តថាអវិជ្ជមានប្រចាំសប្តាហ៍សម្រាប់អ្នកចូលរួមទាំងអស់ដែលស្ថានភាពនៃការចាក់ថ្នាំបង្ការរបស់ពួកគេមិនគ្រប់លក្ខណៈនិងមិនទាន់ពេលវេលា រួមទាំងកុមារដែលចូលរួមប្រកួតព្រមទាំងបុគ្គលិក/គ្រូបង្វឹក/អ្នកស្ម័គ្រចិត្ត។ ប្រសិនបើក្រុមមួយកំណត់ថា ការតម្រូវចាំបាច់ឱ្យកីឡាករទាំងអស់ត្រូវតែពាក់ម៉ាស់ក្នុងអំឡុងពេលដែលមានការប្រឹងប្រែងប្រើកម្លាំងយ៉ាងខ្លាំងនោះ គឺមិនអាចអនុវត្តបានទេ ហើយជាលទ្ធផល សមាជិកនៃក្រុមកីឡាករទាំងអស់ជ្រើសរើសចូលរួមប្រកួតដោយមិនពាក់ម៉ាស់ នោះសមាជិកទាំងអស់គឺតម្រូវចាំបាច់ឱ្យអនុវត្តការធ្វើតេស្តត្រួតពិនិត្យរកមេរោគ COVID-19 ឱ្យបានយ៉ាងហោចណាស់ម្តងក្នុងមួយសប្តាហ៍ ដោយមិនគិតពីស្ថានភាពចាក់ថ្នាំបង្ការឡើយ។ សូមកត់សម្គាល់ថា ខណៈពេលដែលការចម្លងក្នុងសហគមន៍នៃខោនធីនេះនៅតែមានកម្រិតគួរឱ្យកត់សម្គាល់ ឬខ្ពស់នោះ មានការណែនាំយ៉ាងម៉ឺងម៉ាត់ថា អ្នកចូលរួមដែលស្ថានភាពនៃការចាក់ថ្នាំបង្ការរបស់ពួកគេមិនគ្រប់លក្ខណៈនិងមិនទាន់ពេលវេលា ឬអ្នកដែលមិនតែងតែពាក់ម៉ាស់ក្នុងអំឡុងពេលកំពុងអនុវត្តការហាត់សម ពង្រឹងសមត្ថភាព ប្រកួតប្រជែង ឬសម្តែង ត្រូវមានការធ្វើតេស្តរកមេរោគឱ្យបានពីរដងក្នុងមួយសប្តាហ៍។
2. **កីឡានៅខាងក្រៅអគារដែលមានកម្រិតហានិភ័យមធ្យមឬខ្ពស់ សម្រាប់យុវវ័យដែលមានអាយុចាប់ពី 12 ឆ្នាំឡើងទៅ ព្រមទាំងបុគ្គលិក/គ្រូបង្វឹក/អ្នកស្ម័គ្រចិត្ត។** តម្រូវឱ្យមានលទ្ធផលធ្វើតេស្តថាអវិជ្ជមានប្រចាំសប្តាហ៍ សម្រាប់អ្នកចូលរួមទាំងអស់ដែលស្ថានភាពនៃការចាក់ថ្នាំបង្ការរបស់ពួកគេមិនគ្រប់លក្ខណៈនិងមិនទាន់ពេលវេលា រួមទាំងយុវវ័យដែលមានអាយុចាប់ពី 12 ឆ្នាំឡើងទៅដែលចូលរួមប្រកួតព្រមទាំងបុគ្គលិក/គ្រូបង្វឹក/អ្នកស្ម័គ្រចិត្ត។ ការធ្វើតេស្តតាមសាលារៀនប្រចាំសប្តាហ៍បំពេញកាតព្វកិច្ចនេះបាន។

- ❑ មិនមានការណែនាំឱ្យធ្វើតេស្តពិនិត្យតាមដានចំពោះកុមារអាយុក្រោម 12 ឆ្នាំដែលលេងកីឡានៅខាងក្រៅអគារនោះទេ។ ចំពោះកីឡាករដែលនៅក្នុងក្រុមកីឡាដែលមានកម្រិតហានិភ័យមធ្យមនិងខ្ពស់ ដែលមានអាយុក្រោម 12 ឆ្នាំ ហើយត្រូវបានដឹកជញ្ជូនជាទៀងទាត់តាមរយៈឡានក្រុង/ឡានតូច មានការណែនាំឱ្យបង្ហាញលទ្ធផលតេស្តថាអវិជ្ជមានប្រចាំសប្តាហ៍។ ការធ្វើតេស្តតាមសាលារៀនប្រចាំសប្តាហ៍បំពេញកាតព្វកិច្ចនេះបាន។
- ❑ ប្រសិនបើកីឡាករដែលមានអាយុក្រោម 12 ឆ្នាំចូលរួមក្នុងការប្រកួតដែលមានខោនធីច្រើន ហើយរយៈពេលច្រើនថ្ងៃសម្រាប់ប្រភេទកីឡានៅខាងក្រៅអគារដែលប្រឈមនឹងហានិភ័យមធ្យមឬខ្ពស់ មានការណែនាំឱ្យធ្វើតេស្តដែលមានលទ្ធផលអវិជ្ជមានក្នុងរយៈពេល 3 ថ្ងៃជាប់គ្នា[4] មុនពេលការប្រកួតលើកដំបូងរបស់ពួកគេ។
- ❑ មិនចាំបាច់ធ្វើតេស្តពិនិត្យតាមដានមេរោគសម្រាប់អត្តពលិកគ្រប់អាយុ គ្រូបង្វឹក ឬបុគ្គលិកជំនួយក្នុងក្រុមកីឡាដែលមានកម្រិតហានិភ័យមធ្យមឬខ្ពស់នោះទេ ប្រសិនបើក្រុមនេះគ្រាន់តែចូលរួមក្នុងសកម្មភាពពង្រឹងសមត្ថភាព ឬកសាងជំនាញពេលដែលការរក្សាគម្លាតរាងកាយ 6 ហ្វីតត្រូវបានរក្សារវាងអ្នកចូលរួមគ្រប់ពេល។ ការលើកលែងនេះអនុវត្តតែក្នុងអំឡុងពេលដែលមិនមានទំនាក់ទំនង ឬការប៉ះពាល់ជិតស្និទ្ធដែលកំពុងកើតឡើងនៅក្នុងការហាត់សមណាមួយ និងមិនមានការប្រកួតតែប៉ុណ្ណោះ។ ប្រសិនបើមានការហាត់សម ឬការប្រកួតពេញលេញដែលរៀបចំឡើងនៅថ្ងៃជាក់លាក់ណាមួយ នោះតម្រូវការនៃការធ្វើតេស្តនៅតែមាន ទោះបីជាមានតែការហាត់សមផ្សេងៗដែលត្រឹមតែរួមបញ្ចូលការពង្រឹងសមត្ថភាព ឬកសាងជំនាញក៏ដោយ។

  យុវជនដែលកំពុងចូលរួមក្នុងការប្រកួតកីឡានៅខាងក្រៅអគារដែលស្ថានភាពនៃការចាក់ថ្នាំបង្ការរបស់ពួកគេគ្រប់លក្ខណៈនិងទាន់ពេលវេលានោះ មិនចាំបាច់ធ្វើតេស្តរាល់សប្តាហ៍ទេ លើកលែងតែមានករណីវិជ្ជមានក្នុងចំណោមកីឡាករ គ្រូបង្វឹក និង/ឬបុគ្គលិក។ ប្រសិនបើមានករណីវិជ្ជមាន កីឡាករ បុគ្គលិក/គ្រូបង្វឹក/អ្នកស្ម័គ្រចិត្តទាំងអស់ (ដោយមិនគិតពីស្ថានភាពនៃការចាក់ថ្នាំបង្ការ) តម្រូវឱ្យមានបង្ហាញលទ្ធផលតេស្តថាអវិជ្ជមានប្រចាំសប្តាហ៍រយៈពេលពីរសប្តាហ៍ ចាប់ពីពេលដែលមានការប៉ះពាល់នឹងករណីនេះ ហើយត្រូវតែធ្វើតេស្តទទួលលទ្ធផលថាអវិជ្ជមានមុនពេលប្រកួត។

- ❑ បុគ្គលិក/អ្នកស្ម័គ្រចិត្តក្នុងក្រុមដែលតួនាទីឬមុខងារមិនរាប់បញ្ចូលការប្រាស្រ័យទាក់ទងដោយផ្ទាល់ជាមួយអត្តពលិក គ្រូបង្វឹក ឬបុគ្គលិកផ្សេងទៀត (ឧទាហរណ៍ ការផ្តល់ជំនួយផ្នែករដ្ឋបាលដល់ក្រុម ឬសម្ព័ន្ធ ប៉ុន្តែមិនធ្វើការដោយផ្ទាល់ជាមួយក្រុមយុវជន ឬសមាជិកក្រុមផ្សេងទៀត) ត្រូវបានលើកលែងពីតម្រូវការនៃការធ្វើតេស្ត។

---

[4] រយៈពេល 3 ថ្ងៃជាប់គ្នាគឺ 3 ថ្ងៃមុនពេលការប្រកួតអន្តរក្រុម (រវាងក្រុមផ្សេងគ្នា)។ ការប្រើរយៈពេល 3 ថ្ងៃជាប់គ្នាជាជាងរយៈពេល 72 ម៉ោងអាចផ្តល់ភាពបត់បែនច្រើនឱ្យអត្តពលិក ឬបុគ្គលិក។ ដោយប្រើរយៈពេល 3 ថ្ងៃជាប់គ្នា សុពលភាពនៃការធ្វើតេស្តមិនអាស្រ័យលើពេលវេលានៃការប្រកួត ឬពេលវេលានៃថ្ងៃដែលបានធ្វើតេស្តនោះទេ។ ឧទាហរណ៍ ប្រសិនបើការប្រកួតគឺនៅម៉ោង 1 រសៀលថ្ងៃសុក្រ អត្តពលិកឬបុគ្គលិក អាចចូលរួមក្នុងការប្រកួតដោយបង្ហាញលទ្ធផលនៃការធ្វើតេស្តថាអវិជ្ជមាន ដែលត្រូវបានធ្វើឡើងនៅពេលណាមួយកាលពីថ្ងៃអង្គារ ឬថ្ងៃបន្ទាប់មក។

- ❑ អ្នកស្ម័គ្រចិត្តម្តងម្កាល ដែលមានការប្រាស្រ័យទាក់ទងផ្ទាល់កម្រិតតិចណាស់ជាមួយអត្តពលិក គ្រូបង្វឹក ឬបុគ្គលិកផ្សេងទៀត (ឧទាហរណ៍ អាជ្ញាកណ្តាលស្ម័គ្រចិត្ត ឬអាជ្ញាកណ្តាលដែលមកកាត់សេចក្តីតែម្តង ឬពីរដងក្នុងមួយរដូវកាល) នោះ មិនត្រូវបានតម្រូវឱ្យធ្វើតេស្តពិនិត្យតាមដានមេរោគប្រចាំសប្តាហ៍នោះទេ ប៉ុន្តែត្រូវតែមានភស្តុតាងនៃការចាក់ថ្នាំបង្ការពេញលេញប្រឆាំងនឹងជំងឺ COVID-19 ឬភស្តុតាងនៃការធ្វើតេស្តអវិជ្ជមានដែលបានធ្វើឡើយក្នុងអំឡុងពេល 3 ថ្ងៃមុនពេលវេលាធ្វើការស្ម័គ្រចិត្តរបស់ពួកគេ។

## ខ្យល់បក់ចេញចូល

- ❑ ប្រសិនបើសកម្មភាពកីឡាយុវជនត្រូវបានរៀបចំឡើងនៅខាងក្នុងអគារ សូមប្រាកដថាមានប្រព័ន្ធម៉ាស៊ីនកម្តៅ ប្រព័ន្ធខ្យល់ និងម៉ាស៊ីនត្រជាក់រួមគ្នា (HVAC) នៃអគាររបស់អ្នកគឺនៅល្អ មានដំណើរការធម្មតា។
- ❑ សូមពិចារណាតំឡើងម៉ាស៊ីនសម្អាតខ្យល់ដែលមានប្រសិទ្ធិភាពខ្ពស់ហើយអាចចល័តបាន ធ្វើឱ្យតម្រងខ្យល់របស់អគារប្រសើរឡើងហើយឱ្យមានប្រសិទ្ធិភាពខ្ពស់បំផុតតាមដែលអាចធ្វើបាន និងធ្វើការកែប្រែផ្សេងទៀតដើម្បីបង្កើនបរិមាណខ្យល់ពីខាងក្រៅ និងខ្យល់ចេញចូលនៅគ្រប់ទីតាំងធ្វើការ។
- ❑ នៅពេលអាកាសធាតុ និងល័ក្ខខ័ណ្ឌនៃការលេងកីឡាអំណោយផល សូមបង្កើនខ្យល់បរិសុទ្ធពីខាងក្រៅដោយបើកបង្អួច និងទ្វារ។ សូមពិចារណាប្រើកង្ហារដើម្បីបង្កើនប្រសិទ្ធភាពនៃការបើកបង្អួច-ដោយដាក់កង្ហារតាមបង្អួចដើម្បីផ្លុំខ្យល់ចេញទៅខាងក្រៅ មិនមែនចូលខាងក្នុងទេ។
- ❑ នៅពេលមានសកម្មភាពនៅខាងក្នុងអគារកើតឡើង ការធ្វើឱ្យខ្យល់បក់ចេញចូលបានប្រសើរឡើងនៅក្នុងសាលហាត់កីឡា គឺជាមធ្យោបាយដ៏សំខាន់មួយដើម្បីកាត់បន្ថយហានិភ័យនៃការចម្លង និងការផ្ទុះឡើងនៃមេរោគដែលជាលទ្ធផលបង្កមកពីការប្រកួតកីឡាដែលប្រឈមនឹងហានិភ័យខ្ពស់។ ការប្រើប្រាស់កង្ហារតាមក្បួនត្រឹមត្រូវដើម្បីផ្លាស់ប្តូរខ្យល់នៅផ្ទាល់ដី អាចមានឥទ្ធិពលគួរឱ្យកត់សម្គាល់ក្នុងការកាត់បន្ថយហានិភ័យ។ សូមមើល គំរូអនុវត្តល្អបំផុតសម្រាប់ប្រព័ន្ធខ្យល់បក់ចេញចូលនៅសាលហាត់កីឡា សម្រាប់សេចក្តីណែនាំបន្ថែម។
- ❑ កាត់បន្ថយចំនួនមនុស្សនៅក្នុងទីតាំង ដែលមានខ្យល់បក់ចេញចូលខាងពីខាងក្រៅតិចតួច។
- ❑ ប្រសិនបើក្រុម ឬសម្ព័ន្ធកីឡាយុវជនរបស់អ្នកប្រើប្រាស់យានយន្តដឹកជញ្ជូន ដូចជាឡានក្រុងឬឡានតូច មានការណែនាំឱ្យបើកបង្អួចដើម្បីបង្កើនខ្យលបក់ចេញចូលពីបរិយាកាសខាងក្រៅឱ្យបានច្រើន នៅពេលវាមានសុវត្ថិភាពក្នុងការធ្វើបែបនេះ។
- ❑ សូមមើលគេហទំព័រស្តីពី ការណែនាំស្តីទីសម្រាប់ប្រព័ន្ធខ្យល់បក់ចេញចូល តម្រង និងគុណភាពខ្យល់នៅក្នុងបរិយាកាសខាងក្នុងអគារ របស់រដ្ឋនិង ប្រព័ន្ធខ្យល់បក់ចេញចូលនៅក្នុងសាលារៀន និងកម្មវិធីថែទាំកុមារ របស់ CDC។

## រៀបចំគាំទ្រការលាងសម្អាតដៃ

- ❑ ដាក់ស្ថានីយ៍លាងដៃ ឬទឹកអនាម័យលាងដៃនៅច្រកចូល និងខាងក្រៅបន្ទប់ទឹកដែលប្រើរួមគ្នា ដោយមានដាក់ផ្លាកសញ្ញា ដើម្បីជម្រុញឱ្យមានការប្រើប្រាស់។
- ❑ ជម្រុញឱ្យមានការលាងសម្អាតដៃឱ្យបានញឹកញាប់។

## ការទំនាក់ទំនង

- ❑ បិទ ផ្លាកសញ្ញា ដើម្បីឱ្យភ្ញៀវដែលកំពុងចូលទៅទីតាំងរបស់អ្នក ដឹងអំពីគោលការណ៍របស់អ្នក រួមទាំងតម្រូវការឱ្យមនុស្សគ្រប់រូបត្រូវពាក់ម៉ាស់នៅពេលដែលស្ថិតនៅខាងក្នុងអគារ។
- ❑ ប្រើវេទិកាអនឡាញរបស់អ្នក ដើម្បីផ្សព្វផ្សាយគោលការណ៍សុវត្ថិភាពនៃជំងឺ COVID-19 របស់អ្នកទៅដល់សាធារណជនទាំងអស់។

## បង្កើនការប្រុងប្រយ័ត្នបន្ថែមទៀតជុំវិញការធ្វើដំណើរជាក្រុម និងការប្រកួតរវាងក្រុមផ្សេងគ្នា

- ❑ នៅពេលធ្វើដំណើរក្នុងយានយន្តជាមួយសមាជិកក្រុមកីឡាយុវជនដទៃទៀតដែលមិនមែនជាសមាជិកមកពីគ្រួសារតែមួយ សូមពាក់ម៉ាស់ក្នុងអំឡុងពេលធ្វើដំណើរទាំងមូល និងបើកបង្អួច។ នេះរួមបញ្ចូលទាំងនៅពេលជិះតាមរថយន្តគ្រួសាររួមគ្នាផងដែរ។
- ❑ ប្រសិនបើធ្វើដំណើរទៅចូលរួមព្រឹត្តិការណ៍នៅខាងក្រៅខោនធី Los Angeles សូមប្រកាន់ខ្ជាប់នូវ ការប្រឹក្សា និងសេចក្តីណែនាំអំពីការធ្វើដំណើរ។
- ❑ នៅពេលធ្វើដំណើរដោយត្រូវសម្រាកពេលយប់ មានការណែនាំឱ្យសមាជិកក្រុមដែលមិនមែនជាសមាជិកមកពីគ្រួសារដូចគ្នា ត្រូវគេងក្នុងបន្ទប់ដាច់ដោយឡែកពីគ្នា និងបន្តរក្សាការពាក់ម៉ាស់នៅពេលទៅលេងបន្ទប់របស់សមាជិកផ្សេងទៀតនៅក្នុងសណ្ឋាគារនោះ។
- ❑ ការរាប់អានសេពគប់ជាមួយសមាជិកនៃក្រុមផ្សេងទៀតមិនត្រូវបានជម្រុញឱ្យធ្វើនោះឡើយ។

## ការយល់ដឹងអំពីហានិភ័យដែលទាក់ទងនឹងកីឡា ក្នុងអំឡុងពេលផ្ទុះជំងឺរាតត្បាតសកលនេះ

កីឡា និងសកម្មភាពផ្នែករាងកាយដែលអនុញ្ញាតឱ្យរក្សាគម្លាតចាប់ពី 6 ទៅ 8 ហ្វីតរវាងដៃគូប្រកួតផ្សេងទៀត ដូចជា កីឡាវាយកូនហ្គោល ឬកីឡាវាយកូនបាល់ទោលប្រឈមនឹងហានិភ័យទាបជាងកីឡាដែលពាក់ព័ន្ធនឹងទំនាក់ទំនង ឬការប៉ះពាល់ជិតស្និទ្ធជាញឹកញាប់ដូចជាកីឡាបាល់បោះ ឬបោកចំបាប់។ ចំពោះកីឡាដែលអត្តពលិកមិនប្រើសម្ភារៈរួមគ្នា ដូចជាការរត់ប្រណាំង (cross country) ប្រឈមនឹងហានិភ័យទាបជាងប្រភេទកីឡាដែលប្រើសម្ភារៈរួមគ្នា ដូចជាកីឡាបាល់ឱបអាមេរិក។ ប្រភេទកីឡាដែលការប៉ះពាល់តិចតួចទៅនឹងកីឡាករផ្សេងទៀតអាចជាជម្រើសដែលមានសុវត្ថិភាពជាង។ ឧទាហរណ៍ ការរត់ប្រណាំងលើទីវាលសម្រាប់រត់ អាចប្រឈមនឹងហានិភ័យទាបជាងកីឡាដែលធ្វើឱ្យបុគ្គលម្នាក់មានទំនាក់ទំនង ឬការប៉ះពាល់ជិតស្និទ្ធជាមួយកីឡាករផ្សេងទៀតក្នុងរយៈពេលយូរ ដូចជាប្រើពេលវេលាពាក់កណ្តាលនៃការប្រកួតទាំងមូល។

ទីតាំងជាក់លាក់ដែលអត្តពលិកហ្វឹកហាត់ ហាត់សម និងប្រកួត ក៏ជះឥទ្ធិពលដល់ហានិភ័យផងដែរ។ ជ្រើសរើសទីតាំងខាងក្រៅអគារសម្រាប់កីឡា និងថ្នាក់បង្វឹក នៅពេលណាដែលអាចធ្វើទៅបាន។ ជំងឺ COVID-19 ទំនងជាអាចរីករាលដាលនៅក្នុងទីធ្លាខាងក្នុងអគារដែលមិនមានខ្យល់បក់ចេញចូលល្អ។ កីឡា និងសកម្មភាពខាងក្នុងអគារទំនងជាប្រឈមនឹងហានិភ័យខ្ពស់នៃការចម្លងមេរោគ ជាពិសេសប្រសិនបើកីឡា ឬសកម្មភាពរាងកាយនេះ ពាក់ព័ន្ធនឹងទំនាក់ទំនងឬការប៉ះពាល់ជិតស្និទ្ធ ការប្រើឧបករណ៍រួមគ្នា និងការប៉ះពាល់កាន់តែច្រើនរវាងកីឡាករផ្សេងៗ ដូចជាកីឡាបាល់បោះ។

មនុស្សម្នាក់ដែលមានការប្រាស្រ័យទាក់ទងនឹងមនុស្សដទៃទៀតកាន់តែច្រើន គឺកាន់តែមានឱកាសច្រើនក្នុងការប៉ះពាល់នឹងជំងឺ COVID-19។ ដូច្នេះក្រុមតូចៗ ការហ្វឹកហាត់តាមទីតាំងឬថ្នាក់រៀនតូចៗដែលនៅជាមួយគ្នាជាប់ ជាជាងការលាយឡំជាមួយក្រុមផ្សេង គ្រូបង្វឹក ឬគ្រូបង្រៀនផ្សេងទៀត នឹងក្លាយជាជម្រើសដែលមានសុវត្ថិភាពជាង។ នេះក៏នឹងផ្តល់ភាពងាយស្រួលក្នុងការទាក់ទងទៅបុគ្គលទាំងនោះផងដែរ ប្រសិនបើមានការប៉ះពាល់ទៅនឹងជំងឺ COVID-19។

ការស្នាក់នៅក្នុងសហគមន៍របស់អ្នក នឹងមានសុវត្ថិភាពជាងការចូលរួមក្នុងក្រុមធ្វើដំណើរផ្សេងៗ។ ការធ្វើដំណើរទៅកាន់តំបន់ដែលមានករណីជំងឺ COVID-19 ច្រើនអាចបង្កើនឱកាសនៃការឆ្លងមេរោគ និងការរីករាលដាល។ កីឡាដែលត្រូវការធ្វើដំណើរក៏រួមបញ្ចូលកីឡាករចម្រុះផងដែរ ដូច្នេះអត្តពលិកជាទូទៅបានប៉ះពាល់នឹងមនុស្សកាន់តែច្រើន។

## តារាងទី 1៖ ឧទាហរណ៍នៃកីឡាដែលត្រូវបានបែងចែកតាមកម្រិតហានិភ័យ

<table>
<tr><th>ហានិភ័យទាប</th><th>ហានិភ័យមធ្យម</th><th>ហានិភ័យខ្ពស់</th></tr>
<tr>
<td><ul>
<li>កីឡាបាញ់ធ្នូ</li>
<li>កីឡាវាយសី (ទោល)</li>
<li>ក្រុមតន្ត្រី (Band)</li>
<li>កីឡាជិះកង់</li>
<li>ល្បែងបោះកូនបាល់លើទីវាលតូច (Bocce)</li>
<li>ល្បែងបោះប៊ូលីង</li>
<li>ល្បែងបោះកូនកញ្ចប់ចូលរន្ធ (Corn hole)</li>
<li>ការរត់ប្រណាំង (Cross country)</li>
<li>កីឡាបោះដុំមូលលើទឹកកក (Curling)</li>
<li>ការរាំ (មិនមានការប៉ះពាល់)</li>
<li>ល្បែងបោះថាសចូលកន្ត្រក (Disc golf)</li>
<li>ក្រុមភ្លេងស្គរ</li>
<li>ព្រឹត្តិការណ៍ជិះសេះ (រាប់បញ្ចូលទាំងកម្មវិធី rodeos) ដែលមានអ្នកជិះតែម្នាក់ក្នុងម្តង)</li>
<li>កីឡាវាយកូនហ្គោល</li>
<li>កាយសម្ព័ន្ធ (gymnastics)</li>
<li>កីឡាជិះស្គីលើទឹកកក និងជិះស្បែកជើងមានកង់ (គ្មានការប៉ះពាល់)</li>
<li>ល្បែងបោះប៊ូលីងលើវាលស្មៅ</li>
<li>កីឡាបង្ហាញក្បាច់គុន (គ្មានការប៉ះពាល់)</li>
<li>ការហ្វឹកហាត់រាងកាយ [ឧ. យ៉ូហ្គា ហាត់ប្រាណបែបរាំ (Zumba) ថៃជី]</li>
<li>កីឡាវាយកូនបាល់ (ទោល) (Pickleball)</li>
<li>ការចែវទូក/អុំទូក (មានមនុស្ស 1 នាក់)</li>
<li>ការរត់</li>
<li>កីឡារុញដុំថាសដោយដងវែងលើក្តារបន្ទះ (Shuffleboard)</li>
<li>ការបាញ់ថាសដីឥដ្ឋ (Skeet shooting)</li>
<li>ការជិះស្គី និងជិះបន្ទះក្តារលើទឹកកក</li>
<li>ការដើរលើទឹកកក</li>
<li>ការហែលទឹក និងលោតទឹក</li>
<li>កីឡាវាយកូនបាល់ (ទោល) (Tennis)</li>
<li>ការរត់ប្រណាំង</li>
<li>ការដើរ និងឡើងភ្នំ</li>
</ul></td>
<td><ul>
<li>កីឡាវាយសី (ជាគូ)</li>
<li>កីឡាវាយកូនបាល់ដោយដំបង (Baseball)</li>
<li>ការសម្តែងការគាំទ្រជាក្រុម (Cheerleading)</li>
<li>ការរាំ (ដោយមានការប៉ះពាល់ម្តងម្កាល)</li>
<li>កីឡាគប់បាល់ឱ្យចំគូប្រកួត (Dodgeball)</li>
<li>កីឡាវាយកូនគោលលើទីវាល (Field hockey)</li>
<li>កីឡាបាល់ឱបប្រភេទមានទង់ (Flag Football)</li>
<li>ល្បែងបាល់ទាត់ម្យ៉ាងដូចកីឡាវាយកូនបាល់ (Kickball)</li>
<li>កីឡាវាយកូនបាល់មានដងវែងដែលមានសំណាញ់នៅចុង (ក្មេងស្រី/ស្ត្រី) (Lacrosse)</li>
<li>កីឡាវាយកូនបាល់ (ជាគូ) (Pickleball)</li>
<li>កីឡាវាយបាល់ផ្តប់នឹងជញ្ជាំង (Squash)</li>
<li>កីឡាវាយកូនបាល់ដោយដំបងបែបងាយ (Softball)</li>
<li>កីឡាវាយកូនបាល់ (ជាគូ) (Tennis)</li>
<li>កីឡាបាល់ទះ</li>
</ul></td>
<td><ul>
<li>កីឡាបាល់បោះ</li>
<li>កីឡាប្រដាល់</li>
<li>កីឡាបាល់ឱបអាមេរិក</li>
<li>កីឡាវាយកូនគោលលើទឹកកក (Ice hockey)</li>
<li>ជិះស្គីលើទឹកកក (ជាគូ) (Ice Skating)</li>
<li>កីឡាវាយកូនបាល់មានដងវែងដែលមានសំណាញ់នៅចុង (ក្មេងប្រុស/បុរស) (Lacrosse)</li>
<li>កីឡាបង្ហាញក្បាច់គុន</li>
<li>កីឡាជិះស្គីតទល់ជាក្រុម (Roller Derby)</li>
<li>កីឡាបាល់ឱប (Rugby)</li>
<li>ការចែវទូក/អុំទូក (ដោយមានមនុស្ស 2 នាក់ ឬច្រើននាក់)</li>
<li>កីឡាបាល់ទាត់</li>
<li>កីឡាគប់បាល់ក្នុងទឹក (Water polo)</li>
<li>កីឡាបោកចំបាប់</li>
</ul></td>
</tr>
</table>